ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

របាយការណ៍
ស្តីពី
លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី២ ឆ្នាំ២០២១
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២១ សរុបមានចំនួន ៣៥ ៤២៥,៤ លានរៀល ក្នុងនោះ ៖

(ក) រដ្ឋបាលកណ្តាល៖ បានគ្រោងចំណូលសរុបចំនួន ៣៥ ៤២៤ លានរៀល ចំណូលនេះរួមមាន :

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២០ ៩៩២ លានរៀល ស្មើនឹង៧៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ១១ ១៦២ លានរៀល ស្មើនឹង១០៣,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (៣)ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម មានចំនួន៣ ២៧០ លានរៀល ស្មើនឹង១១៤,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ។

(ខ) មន្ទីរាជធានី ខេត្ត៖ បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង ១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការលក់ជួលទ្រព្យសម្បត្តិនិងសេវារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។

II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នៅក្នុងត្រីមាសទី២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូល សរុបមានចំនួន ៩ ៧៣១,៣ លានរៀល ស្មើនឹង២៧,៥ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១១៦,២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

(ក) រដ្ឋបាលកណ្តាល៖ អនុវត្តប្រមូលចំណូល សរុបមានចំនួន៩ ៧៣១,៣លានរៀល ស្មើនឹង២៧,៥ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង១១៦,២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមាន (១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន៤ ៩៧៩,៥ លានរៀល ស្មើនឹង២៣,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១២០,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន៤ ២៤៨,៣ លានរៀល ស្មើនឹង ៣៨,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៤០,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣)ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៥០៣,៤ លានរៀល ស្មើនឹង១៥,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង ៤១,២ % ធៀបនឹងកម្មវិធីដែលបានដាក់ចេញ(៤)ផលហិរញ្ញវត្ថុនិងផលពិសេស មានចំនួន ០,១លានរៀល ។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

(ខ) មន្ទីរាជធានី ខេត្ត ៖

នៅក្នុងត្រីមាសទី២នេះមន្ទីរមិនទាន់បានអនុវត្តចំណូលពីថ្លៃឈ្នួលដីទេ។

ជារួមការអនុវត្តចំណូល របស់រដ្ឋបាលកណ្តាលសម្រេចបានល្អទោះបីជាចំណូលពីការផាកពិន័យអនុវត្តបានទាបជាងត្រីមាសទី១ដែលបណ្តាលមកពីការពិន័យផ្នែកនីតិកម្មកសិកម្ម និងផ្នែកជលផលមានការថយចុះ។ម្យ៉ាងទៀត ដោយពិនិត្យទៅតាមប្រភេទចំណូលនីមួយៗ ឃើញថាមានភាពកើនខ្ពស់ធៀបនឹងកម្មវិធីដែលបានដាក់ចេញជាក់ស្តែងដូចជា៖

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋអនុវត្តបាន២៣,៧%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១២០,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ករណីនេះបណ្តាលមកពីចំណូលពីចំណូលផលពីព្រៃឈើអនុវត្តបាន៤៥,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៦៨,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងចំណូលពីសម្បទានដីសេដ្ឋកិច្ចអនុវត្តបាន ៥,៦%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៤១,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវា អនុវត្តបាន៣៨,១%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង ១៤០,១% នឹងកម្មវិធីដែលបានដាក់ចេញ ។ ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាលនិងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ អនុវត្តបានចំនួន២៦,៨% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៩៦,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ចំពោះការជួលទ្រព្យសម្បត្តិរដ្ឋដូចជា ការជួលដីទំនេរអនុវត្តបាន២៦,៩%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៣៧,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ដីមានអគារអនុវត្តបាន១៩,២%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង ៤៨,៦%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ដោយឡែកចំណូលផលពីការគ្រប់គ្រងរដ្ឋបាលដែលបានពីការត្រួតពិនិត្យអនាម័យសត្ត និងការត្រួតពិនិត្យគុណភាពផលិតផលអនុវត្តបាន៤៣,១%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៥៧,៦%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(៣)ចំណូលពីការផាកពិន័យនិងដាក់ទណ្ឌកម្មអនុវត្តបានទាបជាងត្រីមាសទីមួយ គឺសម្រេចបាន១៥,៤%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៤១,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ លទ្ធផលនេះបានមកដោយសារការផាកពិន័យលើផលិតផលសាច់សត្ត និងការដឹកជញ្ជូនសត្តរបស់អគ្គនាយកដ្ឋានសុខភាពសត្តនិងផលិតកម្មសត្ត អនុវត្តបាន៤៥ % នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១០០%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការទិញ-លក់ដីនិងថ្នាំកសិកម្មខុសច្បាប់ អនុវត្តបាន១៣,៣% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៣៤,៣%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការនេសាទខុសច្បាប់ អនុវត្តបាន១០,៥%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៤២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងការពិន័យលើបទល្មើសព្រៃឈើ អនុវត្តបាន២៦,៩%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៣៨,៨%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។

III-ទិសដៅអនុវត្តបន្ត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាមកម្មវិធីចំណូលប្រចាំត្រីមាសទី៣ ឆ្នាំ២០២១ ដែលមានទឹកប្រាក់សរុបចំនួន៦ ៥៨៤,៣លានរៀល។ កិច្ចការចាំបាច់មួយទៀតដែលក្រសួងត្រូវបន្តអនុវត្តគឺរៀបចំឯកសារកែសម្រួលកម្រងសេវាសាធារណៈ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

IV-សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី២ របស់រដ្ឋបាលកណ្តាលជារួមសម្រេចបានលទ្ធផលល្អប្រសើរគឺលើសផែនការធៀបនឹងកម្មវិធីដែលបានដាក់ចេញទាំងផ្នែកចំណូលពីសេវាសាធារណៈ និងការជួលដីធ្លី អគារ។ ទោះបីជាយ៉ាងនេះក្តី ចំណូលពីថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ចអនុវត្តបានទាបធៀបនឹងកម្មវិធីដែលបានដាក់ចេញដោយសារ

មានបញ្ហាមួយចំនួនដូចជា(១)ការផ្ទៀងផ្ទាត់ពត៌មានក្រុមហ៊ុនជាមួយប្រព័ន្ធ NRMIS នៅអគ្គនាយកដ្ឋានរតនាគារជាតិមានការយឺតយ៉ាវ (២)ក្រុមហ៊ុនភាគច្រើនមិនបានឆ្លើយតបទាន់ពេលចំពោះលិខិតស្នើសុំបង់ថ្លៃឈ្នួលដែលក្រសួងបានរៀបចំ (៣)ការឆ្លងជំងឺកូវីដ-១៩អូសបន្លាយ ធ្វើឲ្យការចុះជំរុញការបង់ចំណូលនេះមិនអាចអនុវត្តបានពេញលេញដូចបណ្តាឆ្នាំមុនៗ។ ម្យ៉ាងទៀតមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺមិនទាន់បានអនុវត្តប្រមូលចំណូលពីថ្លៃឈ្នួលដីទំនេរនៅឡើយដែរ។

ដូច្នេះដើម្បីអនុវត្តប្រមូលចំណូលឲ្យបានតាមផែនការឆ្នាំ២០២១ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលឲ្យបានទាន់ពេលវេលា គួបផ្សំនឹងការប្រតិបត្តិតាមនីតិវិធីថ្មីៗរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបង់ចំណូលចូលថវិកាជាតិ ។

ថ្ងៃពុធ ១៤កើត ខែទុតិយាពាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០២១

រដ្ឋលេខាធិការនិងជាអនុប្រធានក្រុមការងាររៀបចំថវិកា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

របាយការណ៍
ស្តីពី
លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិការប្រចាំត្រីមាសទី២ ឆ្នាំ២០២១
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សេចក្តីផ្តើម:

ឆ្នាំ២០២១ គឺជាឆ្នាំទី៦ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ"ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព"។ ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធីនិងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២១អង្គភាពថវិកា និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥ រាជធានីខេត្ត។

I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។ នៅក្នុងច្បាប់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងឥណទានចំណាយថវិកា ឆ្នាំ២០២១ សរុបមានចំនួន ២៧៧ ៥៥៣ លានរៀល ក្នុងនោះ ៖

(ក) រដ្ឋបាលកណ្តាល៖ បានគ្រោងឥណទានចំណាយថវិកាសរុបចំនួន ១៨០ ២៧៧ លានរៀល រួមមាន៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន ១៦៤ ២៧៧ លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ១៦ ០០០ លានរៀល

(ខ) មន្ទីររាជធានី ខេត្ត ៖បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន ៩៧ ២៧៦ លានរៀល

II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នៅក្នុងត្រីមាសទី២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អនុវត្តចំណាយ តាមអាណត្តិបើកប្រាក់សរុបចំនួន៤៩ ៩២៩,៨ លានរៀល ស្មើនឹង១៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ក្នុងនោះរដ្ឋបាលកណ្តាលអនុវត្តបានចំនួន២០ ៧៨៧លានរៀលស្មើនឹង១១,៥%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង ៦១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ រីឯមន្ទីរាជធានី ខេត្តអនុវត្តបានចំនួន២៩ ១៣៧,៨លានរៀល ស្មើនឹង២៩,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៧៩,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(ក) រដ្ឋបាលកណ្តាល៖

យោងតាមការពិនិត្យចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការឃើញថា ការអនុវត្តចំណាយតាមអាណត្តិបើកប្រាក់របស់រដ្ឋបាលកណ្តាល (២១អង្គភាពថវិកា) សម្រេចបានចំនួន២០ ៧៨៧ លានរៀល គឺអនុវត្តបានទាបជាងឆ្នាំ២០២០ក្នុងរយៈពេល

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

ដូចគ្នាប្រមាណជា៤៤,៥%ដោយក្នុងនោះ (ក)ការទិញ(ជំពូក៦០) អនុវត្តបានចំនួន១ ៧២១,៧ លានរៀលស្មើនឹង៧,១%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៣៦,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន ៨៧៣,៨លានរៀលស្មើនឹង១,៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៤១,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក(ជំពូក៦៤) អនុវត្តបានចំនួន១៣ ១៧៧,៧ លានរៀល ស្មើនឹង១៨,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៦០,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) ឧបត្ថម្ភធន (ជំពូក៦៥) អនុវត្តបានចំនួន៥ ០១៣,៨លានរៀល ស្មើនឹង ២២,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៨៩,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

ម្យ៉ាងទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្តាល ឃើញថាទឹកប្រាក់សរុបចំនួន២០ ៧៨៧ លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់ៃ

(១) បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម និងកសិធុរកិច្ច (កម្មវិធីទី១) ចំនួន២ ១២៩,៩ លានរៀលស្មើនឹង៧,៧%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(២) ជំរុញផលិតកម្មសត្ត និងសុខភាពសត្ត (កម្មវិធីទី២) ចំនួន៥៣៧,៥ លានរៀល ស្មើនឹង៤,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(៣) គ្រប់គ្រងធនធានជលផលនិងការអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន៦៤៨,៩ លានរៀល ស្មើនឹង៤,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(៤) គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ (កម្មវិធីទី៤) ចំនួន ៣៩៨,៤លានរៀល ស្មើនឹង៣,៩ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(៥) បង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស(កម្មវិធីទី៥) ចំនួន១៧ ០៧២,៤ លានរៀលស្មើនឹង ១៧,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

(ខ) មន្ទីររាជធានី ខេត្ត ៃ

ផ្អែកតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ឃើញថាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥រាជធានី ខេត្ត បានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន ២៩ ១៣៧,៨ លានរៀល គឺអនុវត្តបានទាបជាងឆ្នាំ២០២០ក្នុងរយៈពេលដូចគ្នា ប្រមាណជា៨,១% ក្នុងនោះចំណាយលើ (ក)ការទិញ (ជំពូក៦០) អនុវត្តបានចំនួន៥ ៨៧១,៨ លានរៀល ស្មើនឹង៥២,៣ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៩៣,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៤ ៤៤១,២ លានរៀលស្មើនឹង១៩,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៦១,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ) បន្ទុកបុគ្គលិក (ជំពូក៦៤) អនុវត្តបានចំនួន១៤ ៣០៤ ,៦ លានរៀល ស្មើនឹង២៥,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១០១,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) អត្ថប្រយោជន៍សង្គម (ជំពូក៦២) អនុវត្តបានចំនួន៤ ៥២០,៣ លានរៀល ស្មើនឹង៦១,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៨៩,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង) ជំពូក៦៣ (ពន្ធនិងអាករ) មិនទាន់បានអនុវត្តនៅឡើយនៅក្នុងត្រីមាសទី២នេះ។

ម្យ៉ាងទៀតពិនិត្យទៅតាមចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តួលេខអនុវត្តចំណាយថវិកាសរុប ចំនួន ២៩ ១៣៧,៨ លានរៀល ត្រូវបានអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តដូចខាងក្រោមៃ

ឯកតា: រៀល

មន្ទីររាជធានី ខេត្ត	**ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១**	**ការអនុវត្ត ត្រីមាសទី២**	**%ធៀបច្បាប់ ហិរញ្ញវត្ថុ ២០២១**	**%ធៀបកម្មវិធី ត្រីមាសទី២**
បន្ទាយមានជ័យ	3 711 100 000	580 128 561	15.6%	95.2%
បាត់ដំបង	6 489 100 000	1 894 789 829	29.2%	95.9%
កំពង់ចាម	3 949 300 000	773 577 943	19.6%	76.9%

កំពង់ឆ្នាំង	3 878 800 000	1 571 638 000	40.5%	83.6%
កំពង់ស្ពឺ	4 923 900 000	1 660 611 140	33.7%	98.5%
កំពង់ធំ	5 497 900 000	1 271 597 324	23.1%	103.1%
កំពត	3 999 000 000	1 584 624 660	39.6%	99.8%
កណ្តាល	6 180 000 000	1 619 249 204	26.2%	77.7%
កោះកុង	2 498 100 000	1 035 681 601	41.5%	111.1%
ក្រចេះ	3 903 800 000	1 681 464 815	43.1%	140.1%
មណ្ឌលគិរី	2 898 400 000	390 366 450	13.5%	21.4%
រាជធានីភ្នំពេញ	4 333 100 000	987 970 280	22.8%	92.8%
ព្រះវិហារ	2 924 700 000	556 620 000	19 %	46%
ព្រៃវែង	4 515 000 000	1 371 659 319	30.4%	95.9%
ពោធិ៍សាត់	3 875 200 000	1 319 962 900	34.1%	118.3%
រតនគិរី	3 080 700 000	1 614 234 000	52.4%	150.6%
សៀមរាប	5 712 400 000	1 995 957 800	34.9%	95.3%
ព្រះសីហនុ	2 887 000 000	721 907 860	25%	62.5%
ស្ទឹងត្រែង	3 270 000 000	1 881 378 500	57.3%	96%
ស្វាយរៀង	2 894 700 000	713 618 430	24.7%	88.4%
តាកែវ	5 153 600 000	1 123 751 485	21.8%	70.1%
ឧត្តរមានជ័យ	3 007 100 000	689 495 700	22.9%	97.4%
កែប	1 717 500 000	338 139 280	19.7%	60%
ប៉ៃលិន	2 285 800 000	884 371 510	38.7%	89.5%
ត្បូងឃ្មុំ	3 689 800 000	875 052 841	23.7%	96.2%

III-បញ្ហាប្រឈម

យោងតាមការអធិប្បាយខាងលើឃើញថា ការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី២ឆ្នាំ២០២១ សម្រេចបានទាបជាងឆ្នាំ២០២០ ដោយសារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកែសម្រួលនីតិវិធីមួយចំនួន ដើម្បីឆ្លើយតបនឹងការផ្ទុះជំងឺឆ្លងកូវីដ-១៩ ធ្ងន់ធ្ងរ តាមរយៈការចេញនូវប្រកាសនិងសារាចរណែនាំស្តីពីនីតិវិធីថ្មីៗពាក់ព័ន្ធការចំណាយរដ្ឋទេយ្យបុរេប្រទាន ការចំណាយប្រាក់បៃសកកម្មក្នុងនិងក្រៅប្រទេស ការចំណាយរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា សន្និសីទ និងកិច្ចប្រជុំផ្សេងៗ និងការធ្វើវិចារណកម្មនិងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ។ ការងារនេះតម្រូវឲ្យអង្គភាពថវិកានិមួយៗសិក្សាស្វែងយល់ឲ្យបានច្បាស់លាស់ និងត្រូវរៀបចំឯកសារពាក់ព័ន្ធមួយចំនួនទំរាំអាចអនុវត្តការចំណាយបាន។

ទន្ទឹមនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួបបញ្ហាប្រឈមមួយចំនួនដែលធ្វើឲ្យដំណើរការចំណាយមានការយឺតយ៉ាវខ្លះៗ ទាំងចំណាយចរន្តនិងចំណាយមូលធនដែលបញ្ហាលំបាកទាំងនោះមានដូចជា៖

-ការផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភាពយឺតយ៉ាវដែលនាំឲ្យរាំងស្ទះដល់ការងារអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ(ទាំងថវិកាចរន្តនិងមូលធន)។

-ឯកសារគាំទ្រសម្រាប់ជម្រះទូទាត់រដ្ឋទេយ្យបុរេប្រទានរបស់អង្គភាពថវិកាមួយចំនួន មិនទាន់បំពេញបានគ្រប់គ្រាន់និងទាន់ពេលវេលា។

IV-ទិសដៅអនុវត្តបន្ត

អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវខិតខំអនុវត្តចំណាយថវិកាក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាករបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី៣ឆ្នាំ២០២១ ដែលមានទឹកប្រាក់សរុបចំនួន៧៨ ៩៣២ ៥២៧ ០០០ រៀល ក្នុងនោះរួមមាន ៖

ឯកតា: រៀល

ចំណាត់ថ្នាក់សេដ្ឋកិច្ច	រដ្ឋបាលកណ្តាល	មន្ទីរាជធានី ខេត្ត
ជំពូក ៦០ (ការទិញ)	8 900 000 000	3 023 563 000
ជំពូក ៦១ (សេវាកម្ម)	13 700 000 000	9 088 914 000
ជំពូក ៦៤ (បន្ទុកបុគ្គលិក)	21 200 000 000	14 778 943 000
ជំពូក៦២(អត្ថប្រយោជន៍សង្គម)	-	2 411 107 000
ជំពូក ៦៥ (ឧបត្ថម្ភធន)	5 622 000 000	-
ជំពូក ៦៣ (ពន្ធនិងអាករ)	151 000 000	57 000 000
សរុប	**49 573 000 000**	**29 359 527 000**

V-សេចក្តីសន្និដ្ឋាន

ឆ្លងតាមការពិនិត្យវាយតម្លៃការអនុវត្តចំណាយថវិកា ប្រចាំត្រីមាសទី២ របស់អង្គភាពនៃរដ្ឋបាលកណ្តាល ជារួមសម្រេចបាន៦១% នៃកម្មវិធីដែលបានដាក់ចេញ លទ្ធផលនេះបានមកដោយសារការអនុវត្តចំណាយគ្រប់ជំពូក អនុវត្តបានទាបជាងកម្មវិធីដែលបានដាក់ចេញ ទាំងនេះគឺដោយសារ(១)ដំណើរការទូទាត់ចំណាយតាមនីតិវិធីលទ្ធកម្ម ក្នុងកំឡុងពេលនេះនៅមិនទាន់បានទូទាត់ (២) ការទូទាត់ចំណាយបុរេប្រទាន និងរដ្ឋទេយ្យបុរេប្រទានមានតិចតួចបំផុតដោយសារមានការកែសម្រួលនីតិវិធីអនុវត្ត ទន្ទឹមនេះការទូទាត់ចំណាយជំពូក២១ និងចំណាយបង់ពន្ធរថយន្ត (ជំពូក៦៣) មិនទាន់បានអនុវត្តនៅឡើយ។

ចំពោះការអនុវត្តចំណាយថវិការបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមសម្រេចបានល្អបង្គួរ ក្នុងកម្រិត ៧៩,៩%នៃកម្មវិធីដែលបានដាក់ចេញ។ ទោះបីជាយ៉ាងនេះក្តី មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ចំនួនពីរគឺខេត្តមណ្ឌលគិរីនិងខេត្តព្រះវិហារអនុវត្តចំណាយថវិកាបានទាបនៅឡើយ ដែលត្រូវធ្វើការជំរុញនិងកែលម្អបន្ថែមទៀត។

សរុបសេចក្តីមក ការអនុវត្តចំណាយថវិកា តាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមទទួលបានលទ្ធផលបង្គួរ នឹងរំពឹងកើនឡើងក្នុងត្រីមាសបន្ទាប់ប្រសិនបើស្ថានភាពនៃការឆ្លងជំងឺកូវីដ-១៩ បានធូរស្រាល គួបផ្សំនឹងបែបបទ នីតិវិធីពាក់ព័ន្ធចំណាយត្រូវបានរៀបចំបំពេញរួចរាល់និងការទូទាត់ចំណាយតាមនីតិវិធីលទ្ធកម្ម ត្រូវបានអនុវត្ត។

ថ្ងៃ ចន្ទ ១០ កើត ខែ ទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០២១

រដ្ឋលេខាធិការនិងជាអនុប្រធានក្រុមការងាររៀបចំថវិកា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ

របាយការណ៍អនុវត្តចំណាយថវិកាសម្រាប់ត្រីមាសទី២ ឆ្នាំ២០២១
របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត

ជំពូក	ច្បាប់	កម្មវិធី	ចំណាយ			ផលធៀប (%) ការ	ផលធៀប
	ហិរញ្ញវត្ថុ ២០២១	ត្រីមាសទី២	យោងត្រីមាសមុន	ក្នុងត្រីមាស	បូកយោង	អនុវត្តជាក់ស្តែង ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្ត ត្រីមាសទី២ កម្មវិធីត្រីមាស
	1	2	3	4	5	6=4/1	7=4/2
សរុបរួម	**97,276,000,000**	**32,699,065,000**	**16,932,678,634**	**29,137,849,432**	**46,070,528,066**	**29.95%**	**89.11%**
60	11,235,000,000	6,264,217,000	1,329,263,780	5,871,821,041	7,201,084,821	52.26%	93.74%
61	22,550,000,000	7,257,544,000	1,907,675,858	4,441,190,947	6,348,866,805	19.69%	61.19%
64	56,121,000,000	14,140,478,000	13,133,657,396	14,304,578,444	27,438,235,840	25.49%	101.16%
62	7,293,000,000	5,033,026,000	562,081,600	4,520,259,000	5,082,340,600	61.98%	89.81%
63	77,000,000	3,800,000	-	-	-	0.00%	0.00%
០១- សរុបចំណាយថវិកាខេត្តបន្ទាយមានជ័យ							
សរុបរួម	**3,711,100,000**	**609,730,000**	**543,301,439**	**580,128,561**	**1,123,430,000**	**15.63%**	**95.15%**
60	299,200,000	28,600,000	3,802,250	24,797,750	28,600,000	8.29%	86.71%
61	1,143,700,000	69,106,000	51,664,189	17,441,811	69,106,000	1.53%	25.24%
64	2,033,000,000	509,224,000	487,835,000	537,889,000	1,025,724,000	26.46%	105.63%
62	232,400,000		-	-	-	0.00%	#DIV/0!
63	2,800,000	2,800,000	-	-	-	0.00%	0.00%
០២- សរុបចំណាយថវិកាខេត្តបាត់ដំបង							
សរុបរួម	**6,489,100,000**	**1,975,258,000**	**1,786,658,740**	**1,894,789,829**	**3,681,448,569**	**29.20%**	**95.93%**

ជំពូក	ច្បាប់	កម្មវិធី	ចំណាយ			ផលធៀប (%) ការ	ផលធៀប
	ហិរញ្ញវត្ថុ ២០២១	ត្រីមាសទី២	យោងត្រីមាសមុន	ក្នុងត្រីមាស	បូកយោង	អនុវត្តជាក់ស្តែង ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្ត ត្រីមាសទី២ កម្មវិធីត្រីមាស
60	776,500,000	164,033,000	365,415,700	68,635,200	434,050,900	8.84%	41.84%
61	1,107,400,000	341,225,000	118,588,500	384,042,129	502,630,629	34.68%	112.55%
64	4,092,000,000	1,023,000,000	1,302,654,540	956,552,500	2,259,207,040	23.38%	93.50%
62	507,200,000	447,000,000	-	485,560,000	485,560,000	95.73%	108.63%
63	6,000,000	0	-	-	-	0.00%	#DIV/0!
០៣- សរុបចំណាយថវិកាខេត្តកំពង់ចាម							
សរុបរួម	**3,949,300,000**	**1,005,333,000**	**1,043,244,948**	**773,577,943**	**1,816,822,891**	**19.59%**	**76.95%**
60	322,300,000	80,574,000	133,503,960	93,008,690	226,512,650	28.86%	115.43%
61	681,000,000	170,250,000	30,382,558	36,956,753	67,339,311	5.43%	21.71%
64	2,643,000,000	604,509,000	879,358,430	643,612,500	1,522,970,930	24.35%	106.47%
62	300,000,000	150,000,000	-	-	-	0.00%	0.00%
63	3,000,000	-	-	-	-	0.00%	#DIV/0!
០៤- សរុបចំណាយថវិកាខេត្តកំពង់ឆ្នាំង							
សរុបរួម	**3,878,800,000**	**1,879,700,000**	**834,428,100**	**1,571,638,000**	**2,406,066,100**	**40.52%**	**83.61%**
60	505,300,000	375,000,000	12,807,100	343,218,750	356,025,850	67.92%	91.53%
61	995,800,000	731,100,000	90,276,000	560,653,500	650,929,500	56.30%	76.69%
64	2,273,000,000	670,000,000	731,345,000	604,848,750	1,336,193,750	26.61%	90.28%
62	103,600,000	103,600,000	-	62,917,000	62,917,000	60.73%	60.73%
63	1,100,000	-	-	-	-	0.00%	#DIV/0!
០៥- សរុបចំណាយថវិកាខេត្តកំពង់ស្ពឺ							
សរុបរួម	**4,923,900,000**	**1,685,916,000**	**686,608,600**	**1,660,611,140**	**2,347,219,740**	**33.73%**	**98.50%**
60	410,900,000	311,989,000	533,600	302,036,960	302,570,560	73.51%	96.81%

ជំពូក	ច្បាប់	កម្មវិធី	ចំណាយ			ផលធៀប (%) ការ	ផលធៀប
	ហិរញ្ញវត្ថុ ២០២១	ត្រីមាសទី២	យោងត្រីមាសមុន	ក្នុងត្រីមាស	បូកយោង	អនុវត្តជាក់ស្តែង ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្ត ត្រីមាសទី២ កម្មវិធីត្រីមាស
61	955,200,000	178,713,000	-	163,699,500	163,699,500	17.14%	91.60%
64	3,151,000,000	793,114,000	686,075,000	793,144,680	1,479,219,680	25.17%	100.00%
62	403,600,000	402,100,000	-	401,730,000	401,730,000	99.54%	99.91%
63	3,200,000	-	-	-	-	0.00%	#DIV/0!
០៦- សរុបចំណាយថវិកាខេត្តកំពង់ធំ							
សរុបរួម	**5,497,900,000**	**1,233,978,000**	**1,106,888,676**	**1,271,597,324**	**2,378,486,000**	**23.13%**	**103.05%**
60	445,500,000	176,115,000	78,430,600	260,910,400	339,341,000	58.57%	148.15%
61	1,426,400,000	223,835,000	184,114,000	184,802,000	368,916,000	12.96%	82.56%
64	3,316,000,000	773,291,000	783,606,476	795,924,524	1,579,531,000	24.00%	102.93%
62	304,900,000	60,737,000	60,737,600	29,960,400	90,698,000	9.83%	49.33%
63	5,100,000		-	-	-	0.00%	#DIV/0!
០៧- សរុបចំណាយថវិកាខេត្តកំពត							
សរុបរួម	**3,999,000,000**	**1,587,600,000**	**592,854,450**	**1,584,624,660**	**2,177,479,110**	**39.63%**	**99.8%**
60	367,900,000	168,800,000	15,238,950	223,914,660	239,153,610	60.86%	132.7%
61	875,100,000	201,800,000	120,488,000	171,340,000	291,828,000	19.58%	84.9%
64	2,042,000,000	505,000,000	457,127,500	521,625,000	978,752,500	25.54%	103.3%
62	712,000,000	712,000,000	-	667,745,000	667,745,000	93.78%	93.8%
63	2,000,000	-	-	-	-	0.00%	#DIV/0!
០៨- សរុបចំណាយថវិកាខេត្តកណ្តាល							
សរុបរួម	**6,180,000,000**	**2,083,382,000**	**1,495,551,427**	**1,619,249,204**	**3,114,800,631**	**26.20%**	**77.72%**
60	573,800,000	297,900,000	294,595,427	207,999,100	502,594,527	36.25%	69.82%
61	1,162,200,000	405,913,000	201,643,500	187,548,604	389,192,104	16.14%	46.20%

ជំពូក	ច្បាប់	កម្មវិធី	ចំណាយ			ផលធៀប (%) ការ	ផលធៀប
	ហិរញ្ញវត្ថុ ២០២១	ត្រីមាសទី២	យោងត្រីមាសមុន	ក្នុងត្រីមាស	បូកយោង	អនុវត្តជាក់ស្តែង ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្ត ត្រីមាសទី២ កម្មវិធីត្រីមាស
64	4,218,000,000	1,183,569,000	981,312,500	1,028,707,500	2,010,020,000	24.39%	86.92%
62	225,000,000	195,000,000	18,000,000	194,994,000	212,994,000	86.66%	100.00%
63	1,000,000	1,000,000	-	-	-	0.00%	0.00%
០៩- សរុបចំណាយថវិកាខេត្តកោះកុង							
សរុបរួម	**2,498,100,000**	**932,510,000**	**331,615,000**	**1,035,681,601**	**1,367,296,601**	**41.46%**	**111.06%**
60	425,100,000	169,510,000	19,815,000	251,602,290	271,417,290	59.19%	148.43%
61	718,800,000	284,000,000	43,560,000	298,079,311	341,639,311	41.47%	104.96%
64	1,159,000,000	285,000,000	268,240,000	293,240,000	561,480,000	25.30%	102.89%
62	194,000,000	194,000,000	-	192,760,000	192,760,000	99.36%	99.36%
63	1,200,000	-	-	-	-	0.00%	#DIV/0!
១០- សរុបចំណាយថវិកាខេត្តក្រចេះ							
សរុបរួម	**3,903,800,000**	**1,200,000,000**	**358,744,000**	**1,681,464,815**	**2,040,208,815**	**43.07%**	**140.12%**
60	223,000,000	47,000,000	3,520,000	172,535,500	176,055,500	77.37%	367.10%
61	1,076,800,000	480,000,000	130,074,000	134,614,565	264,688,565	12.50%	28.04%
64	2,026,000,000	507,000,000	160,150,000	864,833,750	1,024,983,750	42.69%	170.58%
62	576,000,000	166,000,000	65,000,000	509,481,000	574,481,000	88.45%	306.92%
63	2,000,000	-	-	-	-	0.00%	#DIV/0!
១១- សរុបចំណាយថវិកាខេត្តមណ្ឌលគីរី							
សរុបរួម	**2,898,400,000**	**1,823,740,000**	**300,872,580**	**390,366,450**	**691,239,030**	**13.47%**	**21.40%**
60	552,200,000	548,340,000	11,427,880	8,446,950	19,874,830	1.53%	1.54%
61	678,200,000	634,000,000	41,202,200	60,632,000	101,834,200	8.94%	9.56%
64	1,332,000,000	341,400,000	248,242,500	321,287,500	569,530,000	24.12%	94.11%

ជំពូក	ច្បាប់	កម្មវិធី	ចំណាយ			ផលធៀប (%) ការ	ផលធៀប
	ហិរញ្ញវត្ថុ ២០២១	ត្រីមាសទី២	យោងត្រីមាសមុន	ក្នុងត្រីមាស	បូកយោង	អនុវត្តជាក់ស្តែង ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្ត ត្រីមាសទី២ កម្មវិធីត្រីមាស
62	330,000,000	300,000,000	-	-	-	0.00%	0.00%
63	6,000,000	-	-	-	-	0.00%	#DIV/0!
១២- រាជធានីភ្នំពេញ							
សរុបរួម	**4,333,100,000**	**1,064,652,000**	**824,916,933**	**987,970,280**	**1,812,887,213**	**22.80%**	**92.80%**
60	344,100,000	178,350,000	20,544,433	152,838,280	173,382,713	44.42%	85.70%
61	217,000,000	64,800,000	10,850,000	10,850,000	21,700,000	5.00%	16.74%
64	3,752,000,000	801,502,000	793,522,500	804,286,600	1,597,809,100	21.44%	100.35%
62	20,000,000	20,000,000	-	19,995,400	19,995,400	99.98%	99.98%
63	-		-	-	-	#DIV/0!	#DIV/0!
១៣- សរុបចំណាយថវិការខេត្តព្រះវិហារ							
សរុបរួម	**2,924,700,000**	**1,211,199,000**	**428,751,000**	**556,620,000**	**985,371,000**	**19.03%**	**46.0%**
60	184,200,000	85,600,000	15,800,000	84,587,000	100,387,000	45.92%	98.8%
61	559,700,000	261,492,000	22,754,000	42,092,000	64,846,000	7.52%	16.1%
64	1,847,000,000	533,307,000	390,197,000	299,143,000	689,340,000	16.20%	56.1%
62	330,800,000	330,800,000	-	130,798,000	130,798,000	39.54%	39.5%
63	3,000,000		-	-	0	0.00%	#DIV/0!
១៤- សរុបចំណាយថវិការខេត្តព្រៃវែង							
សរុបរួម	**4,515,000,000**	**1,429,541,000**	**566,879,065**	**1,371,659,319**	**1,938,538,384**	**30.38%**	**95.95%**
60	336,600,000	257,353,000	60,212,681	230,159,319	290,372,000	68.38%	89.43%
61	1,223,400,000	272,188,000	105,796,384	94,466,000	200,262,384	7.72%	34.71%
64	2,753,000,000	700,000,000	400,870,000	848,862,000	1,249,732,000	30.83%	121.27%
62	200,000,000	200,000,000	-	198,172,000	198,172,000	99.09%	99.09%

ជំពូក	ច្បាប់	កម្មវិធី	ចំណាយ			ផលធៀប (%) ការ	ផលធៀប
	ហិរញ្ញវត្ថុ ២០២១	ត្រីមាសទី២	យោងត្រីមាសមុន	ក្នុងត្រីមាស	បូកយោង	អនុវត្តជាក់ស្តែង ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្ត ត្រីមាសទី២ កម្មវិធីត្រីមាស
63	2,000,000	-	-	-	-	0.00%	#DIV/0!
១៥- សរុបចំណាយថវិកាខេត្តពោធិ៍សាត់							
សរុបរួម	**3,875,200,000**	**1,115,766,000**	**780,009,900**	**1,319,962,900**	**2,099,972,800**	**34.06%**	**118.30%**
60	564,600,000	188,400,000	8,780,000	244,629,900	253,409,900	43.33%	129.85%
61	767,700,000	248,700,000	58,353,400	285,452,000	343,805,400	37.18%	114.78%
64	2,157,000,000	559,650,000	687,532,500	533,512,500	1,221,045,000	24.73%	95.33%
62	382,400,000	119,016,000	25,344,000	256,368,500	281,712,500	67.04%	215.41%
63	3,500,000	-	-	-	-	0.00%	#DIV/0!
១៦- សរុបចំណាយថវិកាខេត្តរតនគិរី							
សរុបរួម	**3,080,700,000**	**1,071,700,000**	**381,110,731**	**1,614,234,000**	**1,995,344,731**	**52.40%**	**150.62%**
60	634,000,000	373,800,000	16,738,000	668,992,500	685,730,500	105.52%	178.97%
61	591,400,000	355,000,000	22,190,231	304,270,700	326,460,931	51.45%	85.71%
64	1,516,000,000	239,500,000	342,182,500	378,886,800	721,069,300	24.99%	158.20%
62	332,800,000	103,400,000	-	262,084,000	262,084,000	78.75%	253.47%
63	6,500,000		-	-	-	0.00%	#DIV/0!
១៧- សរុបចំណាយថវិកាខេត្តសៀមរាប							
សរុបរួម	**5,712,400,000**	**2,094,151,000**	**850,277,750**	**1,995,957,800**	**2,846,235,550**	**34.94%**	**95.31%**
60	658,000,000	510,857,000	27,173,150	422,461,300	449,634,450	64.20%	82.70%
61	1,527,400,000	518,558,000	92,442,100	650,334,000	742,776,100	42.58%	125.41%
64	3,284,000,000	910,736,000	730,662,500	843,362,500	1,574,025,000	25.68%	92.60%
62	238,000,000	154,000,000	-	79,800,000	79,800,000	33.53%	51.82%
63	5,000,000	-	-	-	-	0.00%	#DIV/0!

ជំពូក	ច្បាប់	កម្មវិធី	ចំណាយ			ផលធៀប (%) ការ	ផលធៀប
	ហិរញ្ញវត្ថុ ២០២១	ត្រីមាសទី២	យោងត្រីមាសមុន	ក្នុងត្រីមាស	បូកយោង	អនុវត្តជាក់ស្តែង ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្ត ត្រីមាសទី២ កម្មវិធីត្រីមាស
១៨- សរុបចំណាយថវិកាខេត្តព្រះសីហនុ							
សរុបរួម	**2,887,000,000**	**1,155,181,000**	**351,252,693**	**721,907,860**	**1,073,160,553**	**25.01%**	**62.49%**
60	542,700,000	300,000,000	23,600,193	278,636,110	302,236,303	51.34%	92.88%
61	722,100,000	260,000,000	9,250,000	109,891,750	119,141,750	15.22%	42.27%
64	1,310,000,000	305,181,000	318,402,500	333,380,000	651,782,500	25.45%	109.24%
62	311,200,000	290,000,000	-	-	-	0.00%	0.00%
63	1,000,000	-	-	-	-	0.00%	#DIV/0!
១៩- សរុបចំណាយថវិកាខេត្តស្ទឹងត្រែង							
សរុបរួម	**3,270,000,000**	**1,959,400,000**	**0**	**1,881,378,500**	**1,881,378,500**	**57.53%**	**96.02%**
60	909,400,000	834,400,000	-	835,430,900	835,430,900	91.87%	100.12%
61	652,400,000	465,000,000	-	88,250,600	88,250,600	13.53%	18.98%
64	1,404,000,000	360,000,000	-	658,375,000	658,375,000	46.89%	182.88%
62	300,000,000	300,000,000	-	299,322,000	299,322,000	99.77%	99.77%
63	4,200,000		-	-	-	0.00%	#DIV/0!
២០- សរុបចំណាយថវិកាខេត្តស្វាយរៀង							
សរុបរួម	**2,894,700,000**	**807,454,000**	**384,549,700**	**713,618,430**	**1,098,168,130**	**24.65%**	**88.38%**
60	258,700,000	110,180,000	8,902,200	94,132,330	103,034,530	36.39%	85.44%
61	927,900,000	121,500,000	55,295,000	57,248,500	112,543,500	6.17%	47.12%
64	1,485,000,000	371,250,000	320,352,500	364,615,000	684,967,500	24.55%	98.21%
62	218,100,000	204,524,000	-	197,622,600	197,622,600	90.61%	96.63%
63	5,000,000		-	-	-	0.00%	#DIV/0!
២១- សរុបចំណាយថវិកាខេត្តតាកែវ							

ជំពូក	ច្បាប់	កម្មវិធី	ចំណាយ			ផលធៀប (%) ការ	ផលធៀប
	ហិរញ្ញវត្ថុ ២០២១	ត្រីមាសទី២	យោងត្រីមាសមុន	ក្នុងត្រីមាស	បូកយោង	អនុវត្តជាក់ស្តែង ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្ត ត្រីមាសទី២ កម្មវិធីត្រីមាស
សរុបរួម	**5,153,600,000**	**1,603,566,000**	**1,217,213,698**	**1,123,751,485**	**2,340,965,183**	**21.81%**	**70.08%**
60	389,900,000	310,570,000	19,655,575	272,519,685	292,175,260	69.89%	87.75%
61	1,390,300,000	205,801,000	142,780,083	44,747,700	187,527,783	3.22%	21.74%
64	3,045,000,000	775,796,000	1,054,778,040	510,085,000	1,564,863,040	16.75%	65.75%
62	327,000,000	311,399,000	-	296,399,100	296,399,100	90.64%	95.18%
63	1,400,000	-	-	-	-	0.00%	#DIV/0!
២២- សរុបចំណាយថវិកាខេត្តឧត្តរមានជ័យ							
សរុបរួម	**3,007,100,000**	**707,716,000**	**991,345,000**	**689,495,700**	**1,680,840,700**	**22.93%**	**97.43%**
60	294,500,000	21,452,000	128,120,000	15,685,600	143,805,600	5.33%	73.12%
61	1,043,600,000	331,418,000	235,300,000	319,417,600	554,717,600	30.61%	96.38%
64	1,307,000,000	354,846,000.00	269,925,000	354,392,500	624,317,500	27.11%	99.87%
62	358,000,000	-	358,000,000	-	358,000,000	0.00%	#DIV/0!
63	4,000,000	-	-	-	-	0.00%	#DIV/0!
២៣- សរុបចំណាយថវិកាខេត្តកែប							
សរុបរួម	**1,717,500,000**	**563,200,000**	**222,855,000**	**338,139,280**	**560,994,280**	**19.69%**	**60.04%**
60	260,800,000	113,000,000	-	22,179,380	22,179,380	8.50%	19.63%
61	397,200,000	145,200,000	-	36,322,400	36,322,400	9.14%	25.02%
64	1,043,000,000	299,000,000	222,855,000	278,537,500	501,392,500	26.71%	93.16%
62	16,000,000	6,000,000	-	1,100,000	1,100,000	6.88%	18.33%
63	500,000	-	-	-	-	0.00%	#DIV/0!
២៤- សរុបចំណាយថវិកាខេត្តប៉ៃលិន							
សរុបរួម	**2,285,800,000**	**988,372,000**	**363,135,490**	**884,371,510**	**1,247,507,000**	**38.69%**	**89.48%**
60	420,500,000	347,381,000	19,503,480	347,376,520	366,880,000	82.61%	100.00%

ជំពូក	ច្បាប់	កម្មវិធី	ចំណាយ			ផលធៀប (%) ការ	ផលធៀប
	ហិរញ្ញវត្ថុ ២០២១	ត្រីមាសទី២	យោងត្រីមាសមុន	ក្នុងត្រីមាស	បូកយោង	អនុវត្តជាក់ស្តែង ច្បាប់ហិរញ្ញវត្ថុ	ការអនុវត្ត ត្រីមាសទី២ កម្មវិធីត្រីមាស
61	544,800,000	232,749,000	103,849,100	127,881,900	231,731,000	23.47%	54.94%
64	1,177,000,000	283,992,000	234,782,910	284,863,090	519,646,000	24.20%	100.31%
62	140,000,000	124,250,000	5,000,000	124,250,000	129,250,000	88.75%	100.00%
63	3,500,000	-	-	-	-	0.00%	#DIV/0!
២៥- សរុបចំណាយថវិកាខេត្តត្បូងឃ្មុំ							
សរុបរួម	**3,689,800,000**	**910,020,000**	**489,613,714**	**875,052,841**	**1,364,666,555**	**23.72%**	**96.16%**
60	535,300,000	265,013,000	41,143,601	245,085,967	286,229,568	45.78%	92.48%
61	1,164,500,000	55,196,000	36,822,613	70,155,624	106,978,237	6.02%	127.10%
64	1,756,000,000	450,611,000	381,647,500	450,611,250	832,258,750	25.66%	100.00%
62	230,000,000	139,200,000	30,000,000	109,200,000	139,200,000	47.48%	78.45%
63	4,000,000	-	-	-	-	0.00%	#DIV/0!

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ១០ ឆ្នាំ២០២១

អ្នកធ្វើតារាង

បានឃើញ និងឯកភាព
ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ១០ ឆ្នាំ២០២១
ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ

គង់ សុធារី

បានពិនិត្យត្រឹមត្រូវ
ប្រធានការិយាល័យហិរញ្ញកិច្ច

ឃុនទ្ធីកាម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ

របាយការណ៍អនុវត្តចំណាយថវិកាសម្រាប់ត្រីមាសទី២ ឆ្នាំ២០២១
របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ជំពូក	ច្បាប់	ថវិកាកែតម្រូវ	កម្មវិធីត្រីមាសទី២	ចំណាយ			ផលធៀបការអនុវត្ត ត្រីមាសទី២ ច្បាប់ហិរញ្ញវត្ថុ	ផលធៀបការអនុវត្ត ត្រីមាសទី២ កម្មវិធីត្រីមាស
	ហិរញ្ញវត្ថុ ២០២១			យោងត្រីមាសមុន	ក្នុងត្រីមាស	បូកយោង		
	1	2	3	4	5	6	7=5/1	8=5/3
សរុបរួម	**164,277,000,000**	**149,166,400,000**	**43,910,800,000**	**31,443,354,288**	**21,095,145,017**	**52,538,499,305**	**12.84%**	**48.04%**
60	24,133,000,000	21,801,875,000	6,157,700,000	852,529,196	2,029,893,450	2,882,422,646	**8.41%**	**32.97%**
61	45,079,000,000	32,299,525,000	11,481,100,000	356,692,918	873,753,694	1,230,446,612	**1.94%**	**7.61%**
62	60,000,000	60,000,000				-	**0.00%**	**0.00%**
63	291,000,000	291,000,000	50,000,000			-	**0.00%**	**0.00%**
64	72,226,000,000	72,226,000,000	20,600,000,000	23,391,218,450	13,177,715,866	36,568,934,316	**18.25%**	**63.97%**
65	22,488,000,000	22,488,000,000	5,622,000,000	6,842,913,724	5,013,782,007	11,856,695,731	**22.30%**	**89.18%**

ថ្ងៃសុក្រ ៥រោច ខែ ២.គណៈ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ២០២១

អ្នកធ្វើតារាង

បានឃើញ និងឯកភាព
ថ្ងៃសុក្រ ៤រោច ២.គណៈ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ២០២១
ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ

គង់ សុធីរ៉ា

បានពិនិត្យត្រឹមត្រូវ
ប្រធានការិយាល័យហិរញ្ញកិច្ច